ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ :                    មស.

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
## សូមគោរពជូន
## លោកជំទាវ ថេង អាយ អាន្នី សុខ អាន និងក្រុមគ្រួសារ

ខ្ញុំផ្ទាល់ និងភរិយា ថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការស៊ីវិល នៃក្រសួងមុខងារសាធារណៈ មានសេចក្តីក្តុកក្តួល និងសោកស្តាយដ៏ក្រៃលែង បន្ទាប់ពីបានទទួលដំណឹងដ៏ក្រៀមក្រំអំពីមរណភាពរបស់ **សម្តេចវិបុលបញ្ញា សុខ អាន** សមាជិកសភាមណ្ឌលតាកែវ និងជាឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ វេលាពីម៉ោង ១៨.៣២នាទី ក្នុងជន្មាយុ ៦៦ឆ្នាំ ដោយជរាពាធ។

**សម្តេចវិបុលបញ្ញា សុខ អាន** ជាស្វាមី ជាឪពុក និងជាជីតា ជាទីស្រឡាញ់ ប្រកបដោយព្រហ្មវិហារធម៌ និងជាឥស្សរជននយោបាយរបស់រាជរដ្ឋាភិបាលដែលបានរួមចំណែកយ៉ាងសកម្មក្នុងបុព្វហេតុជាតិមាតុភូមិ ដោយបានបូជាកម្លាំងកាយ និងប្រាជ្ញាស្មារតី ក្នុងដំណើរការស្វែងរកសន្តិភាព ការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី លើកកម្ពស់កិត្យានុភាពជាតិលើឆាកអន្តរជាតិ និងនាំមកនូវការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនៅកម្ពុជា។ សមិទ្ធផល និងស្នាដៃជាច្រើន ព្រមទាំងគុណូបការៈរបស់ **សម្តេចវិបុលបញ្ញា** នឹងបានជាចំណេះដឹង និងបទពិសោធន៍សម្រាប់កូនចៅជំនាន់ក្រោយប្រើប្រាស់ជាឧត្តមប្រយោជន៍ជាតិ។

ក្នុងមនោសញ្ចេតនាគោរពស្រឡាញ់ និងក្រៀមក្រំ អាឡោះអាល័យ យើងខ្ញុំសូមចូលរួមរំលែកនូវមរណទុក្ខជាមួយលោកជំទាវ ព្រមទាំងក្រុមគ្រួសារញាតិមិត្តរបស់សព និងសូមឧទ្ទិសដល់វិញ្ញាណក្ខន្ធសព **សម្តេចវិបុលបញ្ញា សុខ អាន** បានសោយសុខក្នុងសុគតិភពកុំបីឃ្លាងឃ្លៀតឡើយ។

សូមលោកជំទាវ និងក្រុមគ្រួសារញាតិមិត្តនៃសព ទទួលនូវសេចក្តីគោរពអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧

**តំណាងថ្នាក់ដឹកនាំមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**